**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៧ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## ស ម្រេ ច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារទេសភាពបន្ទាយឆ្មារ លើផ្ទៃដីទំហំ៦.០០០ ហិកតា(ប្រាំមួយពាន់ហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ **ខេត្តបន្ទាយមានជ័យ** និង **ខេត្តឧត្តរមានជ័យ** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ជាតិ អភិវឌ្ឍន៍ ឌូអិលធីឌី** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៩៧ សជណ.កស ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១១ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***<u>កន្លែងទទួល:</u>***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

<u>ដើម្បីជូនជ្រាប</u>

- ដូចប្រការ៥ "<u>ដើម្បីអនុវត្ត</u>"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

# ផែនទី ទីតាំងដី វិនិយោគ និងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ជាតិអភិវឌ្ឍន៍ ខុអិលធីឌី

## ស្ថិតនៅក្នុង តំបន់ការពារទេសភាពបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ លើផ្ទៃដី ៦០០០ ហ.ត




សញ្ញាសំគាល់

- ផ្លូវជាតិ
- ផ្លូវលើ
- ស្ទឹង . អូរ
- ទីតាំងវិនិយោគ

| Id | N | Coor_x | Coor_y |
|---|---|---|---|
| 1 | A | 285127 | 1563938 |
| 2 | B | 283344 | 1562889 |
| 3 | C | 282681 | 1563896 |
| 4 | D | 281814 | 1566503 |
| 5 | E | 281540 | 1568618 |
| 6 | F | 286400 | 1570886 |
| 7 | G | 285908 | 1572004 |
| 8 | H | 289089 | 1573857 |
| 9 | I | 289578 | 1572466 |
| 10 | J | 289862 | 1572125 |
| 11 | K | 289188 | 1571214 |
| 12 | L | 292581 | 1566314 |
| 13 | M | 287037 | 1562765 |
| 14 | N | 284156 | 1567718 |
| 15 | O | 282999 | 1568461 |
| 16 | P | 282707 | 1568193 |
| 17 | Q | 282926 | 1567042 |
| 18 | R | 282451 | 1566753 |
| 19 | S | 283684 | 1565233 |
| 20 | T | 284128 | 1565427 |

ផែនទី និងនិយាមកានេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...សជណ.កស
ចុះថ្ងៃទី ... ២០១១
ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហ្សាស់ លាស់

ផែនទី និងនិយាមកានេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...
ចុះថ្ងៃទី១៧ខែមករា ឆ្នាំ២០១១
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
ជំនួញនាធិការ